**ព្រះរាជាណាចក្រកម្ពុជា**

ជាតិ សាសនា ព្រះមហាក្សត្រ

**ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ**

**លេខ**: ០១៤/២០ ក.ប/ស.ល.ក.ខ.ល

# សេចក្តីណែនាំ

## ស្តីពី

## ការព្យួរកិច្ចសន្យាការងារ, ការចុះឈ្មោះចូលរៀនជំនាញទន់ និងការផ្អាកបង់ភាគទាន ប.ស.ស. សម្រាប់វិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដែលរងផលប៉ះពាល់ពីកង្វះខាតវត្ថុធាតុដើមដោយសារជំងឺរលាកសួតផ្លូវដង្ហើមប្រភេទថ្មីកូវីដ-១៩

យោងតាមការសម្រេចរបស់រាជរដ្ឋាភិបាល ក្នុងការកាត់បន្ថយផលប៉ះពាល់លើវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដែលខ្វះវត្ថុធាតុដើមពីប្រទេសផ្គត់ផ្គង់វត្ថុធាតុដើម ដោយសារប្រទេសនោះរងផលប៉ះពាល់ជំងឺរលាកផ្លូវដង្ហើមធ្ងន់ធ្ងរខូវីដ-១៩ (CoVid-19) ក្រសួងការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ សូមណែនាំដល់គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង, ម្ចាស់ឬនាយករោងចក្រ, និងកម្មករនិយោជិត អំពីនីតិវិធីសុំព្យួរកិច្ចសន្យាការងារ, ការចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់, និងការស្នើសុំផ្អាកបង់ភាគទាននិងការបន្តផ្តល់តាវកាលិករបស់បេឡាជាតិសន្តិសុខសង្គម (ប.ស.ស.) ដូចខាងក្រោម៖

### ក-ការស្នើសុំព្យួរកិច្ចសន្យាការងារ

យោងស្មារតីនៃមាត្រា៧១ និងមាត្រា៧២នៃច្បាប់ស្តីពីការងារ រោងចក្រដែលខ្វះខាតសម្ភារធ្ងន់ធ្ងរឬការលំបាកជាពិសេសណាមួយ ដែលនាំឱ្យព្យួរសកម្មភាពផលិតកម្មណាមួយ នោះភាគីពាក់ព័ន្ធត្រូវបំពេញតាមនីតិវិធីដូចខាងក្រោម៖

សម្រាប់ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- ដាក់លិខិតស្នើសុំព្យួរកិច្ចសន្យាការងារ ទៅនាយកដ្ឋានអធិការកិច្ចការងារសម្រាប់រោងចក្រនៅរាជធានីភ្នំពេញ ឬទៅមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈខេត្ត សម្រាប់រោងចក្រនៅបណ្តាខេត្ត ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី១ និងទី២ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh
- រៀបចំឱ្យមានការពិភាក្សា និងពន្យល់ដល់កម្មករនិយោជិតអំពីមូលហេតុនៃការស្នើសុំព្យួរកិច្ចសន្យាការងារ និងការផ្តល់ប្រាក់ឧបត្ថម្ភក្នុងរយៈពេលនៃការព្យួរកិច្ចសន្យាការងារ ដែលក្នុងករណីចំពោះមុខនេះ គឺស្មើនឹង ៤០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០

សូមទាញយកឯកសារតាម QR Code នេះ៖
ឬតាម Link នេះ៖ https://bit.ly/32AJpJe

- រៀបចំឱ្យមានឯកសារព្រមព្រៀងជាលាយលក្ខណ៍អក្សរ ជាមួយតំណាងកម្មករនិយោជិត អំពីនីតិវិធីនៃការបើកផ្តល់ប្រាក់ឧបត្ថម្ភរបស់និយោជក (៤០% នៃ ១៩០ដុល្លារអាមេរិក)
- រៀបចំបញ្ជីឈ្មោះកម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារ ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៣ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh ។

សម្រាប់នាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរការងារ និងបណ្តុះបណ្តាលវិជ្ជាជីវៈ ត្រូវ៖

- រៀបចំក្រុមអន្តរាគមន៍ពិសេសយ៉ាងតិច ៥ក្រុម ក្នុងនាយកដ្ឋាន ឬមន្ទីរនីមួយៗ ជាពិសេសមន្ទីរដែលមានទីតាំងរោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដើម្បីតាមដានព័ត៌មានពាក់ព័ន្ធនឹងការព្យួរកិច្ចសន្យាការងារ និងត្រៀមចុះពិនិត្យតាមបណ្តាទីតាំងរោងចក្រ ដែលដាក់ពាក្យស្នើសុំព្យួរកិច្ចសន្យាការងារ
- ចុះទៅដល់ទីតាំងរោងចក្រ ដើម្បីពន្យល់សម្របសម្រួលដល់ភាគីពាក់ព័ន្ធអំពីនីតិវិធីនៃការព្យួរកិច្ចសន្យាការងារនេះ ក្នុងរយៈពេល ២៤ម៉ោង នៃម៉ោងធ្វើការ បន្ទាប់ពីបានទទួលសំណើសុំព្យួរកិច្ចសន្យាការងារពីម្ចាស់ ឬនាយករោងចក្រ
- ចេញលិខិតអនុញ្ញាតឱ្យព្យួរកិច្ចសន្យាការងារ (ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៤ និងទី៥ នៃសេចក្តីណែនាំនេះ) ក្នុងរយៈពេល ២៤ម៉ោង ក្រោយកម្មករនិយោជិតនិងនិយោជកបានបំពេញគ្រប់នីតិវិធី និងមានឯកសារព្រមព្រៀងគ្នាជាមួយតំណាងកម្មករនិយោជិត
- ចម្លងលិខិតអនុញ្ញាតព្យួរកិច្ចសន្យាការងារ ជូនបេឡាជាតិសន្តិសុខសង្គម, ទីភ្នាក់ងារជាតិមុខរបរ និងការងារ, ក្រសួងពាណិជ្ជកម្ម, ក្រសួងឧស្សាហកម្មនិងសិប្បកម្ម, ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, អគ្គនាយកដ្ឋានពន្ធដារ, អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា, និងរដ្ឋបាលរាជធានី-ខេត្ត ដែលពាក់ព័ន្ធ។

សម្រាប់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖

- រៀបចំក្រុមអន្តរាគមន៍ពិសេសយ៉ាងតិច ៥ក្រុម នៅរាជធានីភ្នំពេញ និងតាមមជ្ឈមណ្ឌលការងារនីមួយៗ ជាពិសេសមជ្ឈមណ្ឌលការងារ ដែលស្ថិតក្នុងខេត្តមានទីតាំងរោងចក្រវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ដើម្បីចុះជាមួយមន្ត្រីអធិការកិច្ចការងារនៃនាយកដ្ឋានអធិការកិច្ចការងារ ឬមន្ទីរ រៀបចំទទួលចុះឈ្មោះកម្មករនិយោជិតចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់។

**ខ-ការចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់**

សម្រាប់ម្ចាស់ ឬនាយករោងចក្រ ត្រូវ៖

- សហការ និងជួយជូនដំណឹងដល់កម្មករនិយោជិត ដែលត្រូវព្យួរកិច្ចសន្យាការងារឱ្យចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមផ្ទាល់ របស់រាជរដ្ឋាភិបាលចំនួន ២០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០

- សម្របសម្រួល និងបង្កលក្ខណៈងាយស្រួលដល់កម្មករនិយោជិតចុះឈ្មោះចូលរៀនជាមួយមន្ត្រីនៃទីភ្នាក់ងារជាតិមុខរបរ និងការងារ
- ផ្តល់ទីតាំងសម្រាប់ដំណើរការវគ្គបណ្តុះបណ្តាលនៅក្នុងរោងចក្រ។

សម្រាប់កម្មករនិយោជិត ត្រូវ៖

- ចុះឈ្មោះចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ ដើម្បីទទួលបានប្រាក់ឧបត្ថម្ភបន្ថែមផ្ទាល់របស់រាជរដ្ឋាភិបាល ចំនួន ២០% នៃ ១៩០ដុល្លារអាមេរិក ដែលជាប្រាក់ឈ្នួលអប្បបរមាសម្រាប់ឆ្នាំ២០២០។
- ចូលរៀនឱ្យបានទៀងទាត់ទៅតាមកម្មវិធីបណ្តុះបណ្តាល។

សម្រាប់ទីភ្នាក់ងារជាតិមុខរបរ និងការងារ ត្រូវ៖

- សម្របសម្រួលជាមួយរោងចក្រ ក្នុងការរៀបចំដំណើរការវគ្គបណ្តុះបណ្តាល
- ជូនដំណឹងដល់កម្មករនិយោជិតអំពីកាលវិភាគ និងកម្មវិធីបណ្តុះបណ្តាល
- ផ្តល់ការបណ្តុះបណ្តាលឱ្យមានប្រសិទ្ធភាព និងគុណភាព
- រៀបចំ និងគ្រប់គ្រងបញ្ជីវត្តមានប្រចាំថ្ងៃរបស់កម្មករនិយោជិតដែលចូលរួមក្នុងវគ្គបណ្តុះបណ្តាល។

**គ-ការស្នើសុំផ្អាកបង់ភាគទាន និងការបន្តផ្តល់តាវកាលិករបស់ ប.ស.ស.**

- ម្ចាស់ ឬនាយករោងចក្រត្រូវធ្វើលិខិតជូនដំណឹងអំពីការផ្អាកបង់ភាគទានមក ប.ស.ស. ដូចគំរូមានភ្ជាប់ក្នុងឧបសម្ព័ន្ធទី៦ នៃសេចក្តីណែនាំនេះ និងអាចស្វែងរកបាននៅក្នុងគេហទំព័ររបស់ក្រសួង www.mlvt.gov.kh
- ក្នុងអំឡុងពេលមកចូលរៀនវគ្គបណ្តុះបណ្តាលជំនាញទន់ កម្មករនិយោជិតនឹងបន្តទទួលបានតាវកាលិក ផ្នែកហានិភ័យការងារពី ប.ស.ស.
- ក្នុងអំឡុងពេលព្យួរកិច្ចសន្យាការងារនេះ កម្មករនិយោជិតនឹងបន្តទទួលបានតាវកាលិក ផ្នែកថែទាំសុខភាពពី ប.ស.ស. និងប្រាក់ឧបត្ថម្ភសម្រាប់ពេលសម្រាលកូនពីរាជរដ្ឋាភិបាល (៤០ម៉ឺនរៀលសម្រាប់កូនម្នាក់, ៨០ម៉ឺនរៀលសម្រាប់កូនភ្លោះពីរនាក់, និង១,២លានរៀលសម្រាប់កូនភ្លោះបីនាក់ និងទទួលបានប្រាក់ឧបត្ថម្ភរបស់ **សម្តេចតេជោនាយករដ្ឋមន្ត្រី** និង **សម្តេចកិត្តិព្រឹទ្ធបណ្ឌិត** ចំនួន ៥លានរៀល)។

**ឃ-ការផ្សព្វផ្សាយលទ្ធផលការងាររបស់គម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា**

- លេខាធិការដ្ឋាននៃគណៈកម្មការប្រឹក្សាការងារ (SLAC) ត្រូវសហការជាមួយនាយកគម្រោង និងភាគីពាក់ព័ន្ធនៃគម្រោងរោងចក្រកាន់តែប្រសើរនៅកម្ពុជា (ILO-BFC) ដើម្បីផ្សព្វផ្សាយអំពីវឌ្ឍនភាពវិជ្ជមានជាបន្តបន្ទាប់នៃលក្ខខណ្ឌការងារ សិទ្ធិការងារ និងសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជាដល់កម្មករនិយោជិត សារព័ត៌មានជាតិ-អន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា

- លេខាធិការដ្ឋាននៃគណៈកម្មការប្រឹក្សាការងារ (SLAC) ត្រូវសហការជាមួយបណ្ដាញព័ត៌មាននានា ផលិតរូបភាពវីដេអូឃ្លីប និងខិត្តប័ណ្ណ អំពីចំណាប់អារម្មណ៍របស់កម្មករនិយោជិត និងអ្នកប្រើប្រាស់ផលិតផលពីកម្ពុជា ចំពោះភាពកាន់តែប្រសើរឡើងនៃលក្ខខណ្ឌការងារ សិទ្ធិការងារ និងសេរីភាពអង្គការវិជ្ជាជីវៈនៅកម្ពុជា ដែលកើតចេញពីការប្ដេជ្ញាចិត្តរបស់រាជរដ្ឋាភិបាលក្នុងការភ្ជាប់ការធ្វើពាណិជ្ជកម្ម ទៅនឹងលក្ខខណ្ឌការងារ និងការអនុញ្ញាតឱ្យមានគម្រោង ILO-BFC នៅកម្ពុជា ដែលបច្ចុប្បន្នបានក្លាយទៅជាគំរូសម្រាប់អង្គការអន្តរជាតិខាងការងារ (ILO) យកទៅប្រើប្រាស់ និងលើកទឹកចិត្តបណ្ដាប្រទេសផ្សេងទៀតឱ្យយកគំរូតាមកម្ពុជា។

ទទួលបានសេចក្ដីណែនាំនេះ គ្រប់ប្រធានអង្គភាពក្រោមឱវាទក្រសួង, ម្ចាស់ ឬនាយករោងចក្រ, និងកម្មករនិយោជិតនៃវិស័យវាយនភណ្ឌ កាត់ដេរ ផលិតស្បែកជើង និងផលិតផលធ្វើដំណើរនិងកាបូប ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងប្រកបដោយស្មារតីទទួលខុសត្រូវខ្ពស់ ចាប់ពីថ្ងៃចុះហត្ថលេខានេះតទៅ។

ថ្ងៃ សុក្រ ៦កើត ខែផល្គុន ឆ្នាំកុរ ឯកស័ក ព.ស.២៥៦៣

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី ២៨ ខែកុម្ភៈ ឆ្នាំ២០២០

**រដ្ឋមន្ត្រី**

[signature]

**អ៊ិត សំហេង**

**កន្លែងទទួល:**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច ឯកឧត្តម លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ក្រសួងមហាផ្ទៃ
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងឧស្សាហកម្ម និងសិប្បកម្ម
- ក្រសួងពាណិជ្ជកម្ម
- គ្រប់អង្គការវិជ្ជាជីវៈ

    «ដើម្បីជូនជ្រាប»

- ឯកសារ កាលប្បវត្តិ